**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អជសដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១២

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 16-Aug-2012, 16:00
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ញត្តិរបស់ អៀង សារី សុំលុបចោលសេចក្តីជូនដំណឹងនៃដំហររបស់សហព្រះរាជអាជ្ញា លើបញ្ហាសំខាន់ៗដែលត្រូវពិភាក្សានៅកិច្ចប្រជុំរៀបចំសវនាការនៅថ្ងៃទី១៧ ខែសីហា និងឧបសម្ព័ន្ធរបស់ខ្លួន ឬជាជម្រើសមួយផ្សេងទៀត ស្នើសុំឆ្លើយតប**

---

<u>ដាក់ដោយ៖</u>

**សហមេធាវីរបស់លោក អៀង សារី**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

<u>ផ្ញើជូន៖</u>

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន

ចៅក្រម យូរ ឧត្តរ៉ា

ចៅក្រម យ៉ា សុខន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

ចៅក្រមបំរុង ធូ មណី

ចៅក្រមបំរុង Claudia FENZ

<u>ផ្ញើជូន៖</u>

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

លោក **អៀង សារី** តាមរយៈសហមេធាវីរបស់គាត់ (“មេធាវីការពារក្តី”) តទៅនេះសូមលុបចោលសេចក្តីជូនដំណឹងពីជំហររបស់សហព្រះអាជ្ញាលើបញ្ហាសំខាន់ៗ ដែលត្រូវពិភាក្សានៅកិច្ចប្រជុំរៀបចំសវនាការនៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១២ (ជាមួយឧបសម្ព័ន្ធ ក សំងាត់)(“សេចក្តីជូនដំណឹង”)[1] ឬជាជម្រើសមួយផ្សេងទៀត ស្នើសុំការអនុញ្ញាតឆ្លើយតបទៅនឹងសេចក្តីជូនដំណឹងនេះ ក្នុងរយៈពេល១០ថ្ងៃ បន្ទាប់ពីជូនដំណឹងថា ញត្តិសុំលុបចោលនេះ ត្រូវបានបដិសេធ។ សារណានេះត្រូវធ្វើឡើងជាចាំបាច់ពីព្រោះសហព្រះរាជអាជ្ញាមិនគោរពយ៉ាងក្រឡែតលើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការលើកបញ្ហាណាមួយសម្រាប់ពិភាក្សានៅកិច្ចប្រជុំរៀបចំសវនាការ *“ទៅមន្ត្រីច្បាប់ជាន់ខ្ពស់”* និង *“មិនឲ្យហួសពីថ្ងៃសុក្រ ទី១០ ខែសីហា ឆ្នាំ២០១២”*[2]។ អង្គជំនុំជម្រះសាលាដំបូងបានកំណត់កាលបរិច្ឆេទមួយសប្តាហ៍នៅមុនកិច្ចប្រជុំរៀបចំសវនាការ ដើម្បីធានាថាអង្គជំនុំជម្រះ និងភាគីទាំងអស់ទទួលបានការជូនដំណឹងគ្រប់គ្រាន់ពីបញ្ហានានា ដែលភាគីចង់លើកយកមកពិភាក្សា ។ នៅថ្ងៃសុក្រ ទី១០ ខែសីហា ឆ្នាំ២០១២ សហព្រះរាជអាជ្ញារង William Smith បានផ្ញើសារអេឡិកត្រូនិចមកមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងចម្លងជូនភាគីទាំងអស់ ដែលមានខ្លឹមសារថា “សហព្រះរាជអាជ្ញាថ្លែងថាពួកគេពុំមានបញ្ហាបន្ថែមដែលពួកគេមានបំណងលើកឡើង ក្រៅតែពីបញ្ហាដែលកើតចេញពីបញ្ហាដែលឡើងដោយអង្គជំនុំជម្រះសាលាដំបូងនៅក្នុងឯកសារ E218”[3]។ ប៉ុន្តែកាលពីរសៀលម្សិលម៉ិញ កសព បានដាក់ការជូនដំណឹងកម្រាស់ ១៥ទំព័រនៅតែមួយថ្ងៃពេញនៅមុនកិច្ចប្រជុំរៀបចំសវនាការតែប៉ុណ្ណោះ។ សេចក្តីជូនដំណឹងនេះណែនាំនូវបញ្ហាសំខាន់ថ្មីសម្រាប់កិច្ចប្រជុំរៀបចំសវនាការ រួមទាំងសំណើសុំបន្ថែមសាក្សី[4] និងសំណើសុំការកំណត់កាលបរិច្ឆេទសំរាប់ការជំនុំជម្រះដែលសេសសល់ក្នុងសំណុំរឿង ០០២/០១ រួមទាំងសាក្សីដែលត្រូវស្តាប់សក្ខីកម្មលំដាប់លេខរៀងរបស់ពួកគេ កាលបរិច្ឆេទ និងថេរវេលាដើម្បីស្តាប់សក្ខីកម្មលើការបង្ហាញឯកសារ និង

---

[1] សេចក្តីជូនដំណឹងនៃជំហររបស់សហព្រះរាជអាជ្ញាលើបញ្ហាសំខាន់ៗដែលត្រូវពិភាក្សានៅកិច្ចប្រជុំរៀបចំសវនាការនៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១២ (ព្រមជាមួយឧបសម្ព័ន្ធសំងាត់ ក) ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១២ E218/2 ។

[2] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំណបូងស្តីពីការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការដើម្បីជួយដល់ការធ្វើផែនការសំរាប់ដំណាក់កាលនៃការជំនុំជម្រះដែលនៅសេសសល់ក្នុងសំណុំរឿង ០០២/០១ និងការអនុវត្តវិធានការបន្ថែម ដើម្បីលើកកំពស់ប្រសិទ្ធភាពសវនាការ” ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០១២ E218/2.1 នៅទំព័រ ៦។

[3] សារអេឡិកត្រូនិចពីសហព្រះរាជអាជ្ញារង William Smith ទៅកាន់មន្ត្រីច្បាប់ជាន់ខ្ពស់ Susan Lamb ស្តីពី “កិច្ចប្រជុំរៀបចំសវនាការ” ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១២ ។

[4] សេចក្តីជូនដំណឹងនៅកថាខណ្ឌទី១០ ។

ការជំទាស់ឯកសារ[5] ។

កសព មិនបានស្នើសុំការអនុញ្ញាតដើម្បីដាក់សេចក្តីជូនដំណឹងនេះឡើយ និងមិនបានផ្តល់យុត្តិកម្មអ្វីទាំងអស់ ចំពោះភាពយឺតយ៉ាវក្នុងការដាក់សារណា ឬការដាក់ឯកសារផ្លូវការរបស់ខ្លួន ក្រៅតែពីការដាក់ការជូនដំណឹងទៅកាន់មន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់តាមការណែនាំប៉ុណ្ណោះ។ កសព ធ្វើហាក់បីដូចជាខ្លួនទទួលបានបទដ្ឋានមួយផ្សេងពីភាគីដទៃទៀត។ កសព កំពុងព្យាយាមធ្វើការតស៊ូមតិដើម្បីឲ្យគេគាំទ្រជំហររបស់ខ្លួន *បន្ទាប់ពី*ខ្លួនបានដឹងជំហររបស់ភាគីនិមួយៗរួចមក។ ផ្ទុយទៅវិញ ប្រសិនបើ កសព ដាក់ការជូនដំណឹងនេះគ្រាន់តែដើម្បីផ្តល់ឲ្យសាធារណជននូវព័ត៌មានទាក់ទងនឹងជំហររបស់ខ្លួន នោះ កសព គួរតែបានស្នើសុំឲ្យរៀបចំកិច្ចប្រជុំរៀបចំសវនាការនេះជាសាធារណៈ ដូចអ្វីដែលភាគី *ទាំងអស់* ដទៃទៀតបានធ្វើ[6]។

**អាស្រ័យហេតុនេះ** សម្រាប់មូលហេតុដូចបានគូសបញ្ជាក់ក្នុងសំណើនេះ មេធាវីការពារក្តីសូមស្នើដោយគោរព ឲ្យអង្គជំនុំជម្រះសាលាដំបូងច្រានចោលការជូនដំណឹងអំពីជំហររបស់សហព្រះរាជអាជ្ញាលើបញ្ហាសំខាន់ៗ ដែលត្រូវលើកយកមកពិភាក្សាក្នុងកិច្ចប្រជុំរៀបចំសវនាការនៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១២ (ជាមួយនឹងឧបសម្ព័ន្ធ ក សម្ងាត់ ) ឬជាជម្រើសមួយផ្សេងទៀត អនុញ្ញាតឲ្យមេធាវីការពារក្តីឆ្លើយតបទៅនឹងការជូនដំណឹងនេះក្នុងរយៈពេល១០ថ្ងៃ បន្ទាប់ពីមានការជូនដំណឹងថាញត្តិសុំលុបចោលនេះ ត្រូវបានបដិសេធចោល។

សូមចៅក្រមអង្គជំនុំជម្រះសាលាដំបូងទទួលយកសំណើនេះដោយក្តីគោរព។

---

[5] ដូចខាងលើ ឧបសម្ព័ន្ធសំងាត់ ក E218/2.1 ។

[6] សូមមើល សារអេឡិចត្រូនិចពីក្រុមមេធាវីការពារក្តីលោក អៀង សារី ទៅកាន់មន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់របស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា “កិច្ចប្រជុំត្រៀមរៀបចំសវនាការ”, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១២។ សារអេឡិចត្រូនិចពីក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ទៅកាន់មន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់របស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា “កិច្ចប្រជុំត្រៀមរៀបចំសវនាការ” ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១២។ សារអេឡិចត្រូនិចពីក្រុមមេធាវីការពារក្តីលោក នួន ជា ទៅកាន់មន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់របស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា “កិច្ចប្រជុំរៀបចំសវនាការ” ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១២។ សារអេឡិចត្រូនិចពីមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅកាន់មន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់របស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា “កិច្ចប្រជុំត្រៀមរៀបចំសវនាការ” ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១២។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **១៦** ខែ **សីហា** ឆ្នាំ **២០១២**

______________________ ______________________

**អាង ឧត្តម** Michael G. KARNAVAS

សហមេធាវីរបស់លោក **អៀង សារី**